ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

លេខ លេ.ធ.ស.០២៦.០១.ប្រកាសព័ត៌មាន

## សេចក្តីប្រកាសព័ត៌មាន

ធនាគារជាតិនៃកម្ពុជា សូមជម្រាបជូនសាធារណជនឱ្យបានជ្រាបថា នាពេលថ្មីៗនេះមានព័ត៌មានចចាមអារ៉ាម និងគ្មានប្រភពច្បាស់លាស់ត្រូវបានផ្សព្វផ្សាយតាមបណ្តាញសង្គម ដោយបានអះអាងថា ធនាគារមួយចំនួននឹងត្រូវបានបង្កកសាច់ប្រាក់ ឬនឹងត្រូវបានបិទដោយធនាគារជាតិនៃកម្ពុជា។ ជាក់ស្តែង គណនីហ្វេសប៊ុករបស់ឈ្មោះ **មាន សំណាង** (https://www.facebook.com/share/17JnXBYrdv/?mibextid=wwXIfr) និងគណនីតេឡេក្រាមរបស់ឈ្មោះ **Heng Sok** (@WRW_Sokheng) បានផ្សព្វផ្សាយព័ត៌មានមានខ្លឹមសារញុះញង់ឱ្យមានការដកប្រាក់ពីធនាគារ ដែលព័ត៌មានទាំងនេះមិនមានការពិត បង្កចលាចល មានចេតនាបង្កអស្ថិរភាពក្នុងប្រព័ន្ធធនាគារ និងអាចបង្កឱ្យមានភាពរឹតត្បិតធ្ងន់ធ្ងរដល់សន្តិសុខសង្គម។

ការផ្សព្វផ្សាយព័ត៌មានមិនពិត ឬបំភ្លៃព័ត៌មានដោយចេតនា ដែលប៉ះពាល់ដល់ទំនុកចិត្តសាធារណជន និងស្ថិរភាពរបស់ប្រព័ន្ធធនាគារ ជាការធ្វើវិទ្ធង្សនាសេដ្ឋកិច្ច និងបំពានច្បាប់យ៉ាងធ្ងន់ធ្ងរ។ ក្នុងន័យនេះ ធនាគារជាតិនៃកម្ពុជាកំពុងសហការជាមួយអាជ្ញាធរមានសមត្ថកិច្ច ដើម្បីស្រាវជ្រាវ និងកំណត់អត្តសញ្ញាណបុគ្គល ដែលបានផ្សព្វផ្សាយខ្លឹមសារខាងលើឱ្យមកទទួលទោសតាមច្បាប់។

ធនាគារជាតិនៃកម្ពុជា បាន និងកំពុងបន្តបំពេញមុខងារការកិច្ចយ៉ាងពេញលេញក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ដើម្បីរក្សាស្ថិរភាពរបស់ប្រព័ន្ធធនាគារទាំងមូល។ ទន្ទឹមនេះ ធនាគារជាតិនៃកម្ពុជាសូមអំពាវនាវដល់សាធារណជនសូមមេត្តាកុំផ្សព្វផ្សាយ ឬចែកចាយបន្តនូវព័ត៌មានដែលគ្មានមូលដ្ឋាន និងសូមប្រើប្រាស់តែព័ត៌មានផ្លូវការដែលមានប្រភពច្បាស់លាស់ ជាពិសេសព័ត៌មានផ្សព្វផ្សាយដោយធនាគារជាតិនៃកម្ពុជា ឬអាជ្ញាធរពាក់ព័ន្ធ។

*ថ្ងៃពុធ ១៣រោច ខែចេត្រ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៦៩*
*រាជធានីភ្នំពេញ ថ្ងៃទី១៥ ខែមេសា ឆ្នាំ២០២៦*

**ទំនាក់ទំនង ៖**
អង្គភាពទំនាក់ទំនង ធនាគារជាតិនៃកម្ពុជា
(៨៥៥) ២៣ ៩៩០ ១៨៤
nbccommunications@nbc.gov.kh | www.nbc.gov.kh
ធនាគារជាតិ នៃកម្ពុជា - National Bank of Cambodia | National Bank of Cambodia
National Bank of Cambodia | nbccambodia
Natonal Bank of Cambodia | nationalbankofcambodia_
ប្រអប់សំបុត្រលេខ ២៥, ទូរស័ព្ទលេខ ៨៨ ផ្លូវលេខ ១០២ កែងនឹងផ្លូវលេខ ១៩ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ , ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ / ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧